00322256

E1/16.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃដំណើរការនីតិវិធីនៃសវនាការលើអង្គសេចក្តី**
**ក្នុងសំណុំរឿងលេខ ០០១**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៩-ថ្ងៃទីដប់ពីរ

**សាធារណៈ**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

រៀបចំដោយ: សែ គុលវុឌ្ឍី និង Natacha Wexels-Riser

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖លោក Crippa MATTEO,លោកស្រី សែ គុលវុឌ្ឍី,កញ្ញា Natacha Wexels-Riser លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក តាន់ សេណារ៉ុង, លោក Alexander Bates, លោក ពេជ្រ សម្បត្តិ,លោក ប៉ាក ចន្ទលីណ្យ,លោក Stuart Ford |

TRIAL CHAMBER / CHAMBRE DE PREMIÈRE INSTANCE · E C C C

| |
|---|
| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក Francois Roux,លោក ការ សាវុត្ថ, លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ,កញ្ញា Lucile Nattiez ,កញ្ញា Virginie CHARPENTIER។ |
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖លោក គង់ ពិសី,លោក យ៉ុង ផានិត, លោក ហុង គឹម សួន,កញ្ញា Silke Studzinsky,កញ្ញា ទី ស្រីនណា,លោក គឹម ម៉េងឃី,លោក Philippe Canonne,លោក Alain Werner |
| មន្ត្រីតុលាការ/អង្គភាពគ្រប់គ្រងតុលាការ៖ លោក ខូវ កែវរតនៈ |
| ផ្នែកផ្សេងៗ៖ លោកស្រី Julie Masse, លោក ឡាយ ណារ៉ា,លោក ខែម លីនដារីតា, លោកPierre Cozette |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃ ទី ២៧ ខែមេសា ឆ្នាំ ២០០៩ ព្រឹក | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.២៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១០.៣០ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាក អាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖១២.០៥ | បញ្ចប់ម៉ោង៖១៣.៤០ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៥.០០ | បញ្ចប់ម៉ោង៖ ១៥.២៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង នឹង ៥០ នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| វិធាន ៩២ ការដាក់សេចក្តីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល ដាក់ដោយសហព្រះរាជអាជ្ញា | មេធាវីការពារក្តី,សហព្រះរាជអាជ្ញា,មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១,២,៣ និង៤ | ០៩.០៥ | ០៩.៣០ |
| សិទ្ធិរបស់ភាគីក្នុងការពិភាក្សាជាមួយជនជាប់ចោទនៅក្រៅសវនាការ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ និងមេធាវីការពារក្តី | ០៩.៣០ | ៩.៤៥ |
| ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ០៩.៤៥ | ១០.៣០ |

| | | | |
|---|---|---|---|
| សេចក្ដីសម្រេចទៅលើសំណើសុំដែលបានលើកក្នុងអំឡុងពេលសវនាការពេលព្រឹក | អង្គជំនុំជម្រះ | ១១.០៥ | ១១.២០ |
| ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ១១.២០ | ១៤.២៥ |
| សំណើសុំពន្យាពេលវេលាកំណត់ក្នុងការដាក់ជូនឯកសារ | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី២ | ១៥.២៥ | ១៥.៣០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធី៖**

**វិធាន ៩២ ការដាក់សេចក្ដីសន្និដ្ឋានរហូតដល់ពេលបិទកិច្ចពិភាក្សាដេញដោល ដាក់ដោយសហព្រះរាជអាជ្ញា**

- មេធាវីការពារក្ដីបានជំទាស់ក្នុងការដកស្រង់នៃឯកសារផ្សេងៗដែលបានដាក់កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០០៩ ដោយសហព្រះរាជអាជ្ញា។
- សហព្រះរាជអាជ្ញាបានធ្វើការបញ្ជាក់ថា ការដាក់ឯកសារនេះធ្វើឡើងតាមសំណើរបស់អង្គជំនុំជម្រះក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ ឬ សវនាការបឋមដែលត្រូវផ្ដល់ការជូនដំណឹងជាមុននូវឯកសារណាដែលមានបំណងក្នុងការផ្ដល់ឱ្យ និងដើម្បីជួយសម្រួលដល់អង្គជំនុំជម្រះផងដែរ ។ មានក្នុងសំណុំរឿងទេ ជាឯកសារដែលដកស្រង់តែមួយផ្នែកប៉ុណ្ណោះនៅក្នុងសំណុំរឿង។ សហព្រះរាជ អាជ្ញាបានស្នើសុំធ្វើការបញ្ជាក់ពីឯកសារដែលពួកគេមានបំណងផ្ដល់ជូននោះ ។
- មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១,២ និង៤ បានគាំទ្រចំពោះទឡ្ហីករណ៍ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។
- មេធាវីការពារបានឆ្លើយតបថា សហព្រះរាជអាជ្ញាបានដាក់ឯកសារដែលដកស្រង់នេះមុនពេលមានការសម្រេចពីអង្គជំនុំជម្រះ ដែលនេះជាតួនាទីរបស់អង្គជំនុំជម្រះក្នុងការធ្វើស្នើសុំមុន។
- អង្គជំនុំជម្រះបានសម្រេចថាភាគីទាំងអស់មានសិទ្ធិចងក្រងរាល់ឯកសារទាំងអស់ និងរួមផ្គុំហើយចែកជូនដល់អង្គជំនុំជម្រះនឹងភាគី។ ដើម្បីសម្រួលដល់ដំណើរការនីតិវិធីឱ្យមានភាពរលូន



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

ស្រួល ប្រសិនបើភាគីមានបំណងយកឯកសារមកដេញដោល នៅចំពោះមុខអង្គជំនុំជម្រះ សូមផ្តល់ដំណឹងមកក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។ បន្ថែមពីលើចំណុចនេះភាគីទាំងអស់មិនគួរផ្តល់យោបល់ ឬធ្វើការវិភាគទៅលើឯកសារដែលបានចងក្រងនោះទេ ។

**សំណើបន្ថែមដែលបានលើកឡើងដោយមេធាវីក្រុមទី១**

- មេធាវីក្រុមទី១ បានយោងទៅលើវិធាន ៩០.១ និងបានស្នើថាក្នុងអំឡុងពេលនៃការតាំងសំណួរទៅជនជាប់ចោទ គ្មានភាគីណា រួមទាំងមេធាវីការពារក្តី អាចពិភាក្សាជាមួយជនជាប់ចោទអំពីចម្លើយដែលត្រូវផ្តល់ក្នុងពេលសវនាការនោះទេ ។
- មេធាវីការពារបានរំលឹកឡើងវិញថា ជនជាប់ចោទមិនបានធ្វើសម្បថនោះទេ ហើយមេធាវីការពារក្តីអាចទំនាក់ទំនងដោយសេរីជាមួយជនជាប់ចោទទៅលើគ្រប់បញ្ហាទាំងអស់ រួមទាំងអ្វីដែលបាននិយាយក្នុងពេលសវនាការផងដែរ។
- អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីទាំងអស់ថានឹងសម្រេចពីបញ្ហានេះនៅពេលក្រោយ។

**ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ**

- អង្គជំនុំជម្រះបានបន្តតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ
- អង្គជំនុំជម្រះបានយោងទៅលើឯកសារលេខ D30
- ជនជាប់ចោទបានយោងទៅលើឯកសារលេខ D32/IV-ឧបសម្ព័ន្ធ ២៤,ឯកសារលេខ D 93/III ឯកសារលេខ D32/IV-ឧបសម្ព័ន្ធ១៨,ឯកសារលេខ D32/IV-ឧបសម្ព័ន្ធ ៤១ និងឯកសារលេខ D32/IV-ឧបសម្ព័ន្ធ៩

**សំណើសុំពន្យារយៈពេលកំណត់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ ក្នុងការដាក់ចម្លើយតបទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១**

- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ បានស្នើសុំពន្យាពេលកំណត់ក្នុងការដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ដែលស្នើឱ្យចង្អុលបង្ហាញដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមរបស់ពួកគេ នៅលើទំព័រដំបូងនៃសេចក្តីសន្និដ្ឋានរបស់ពួកគេ។
- អង្គជំនុំជម្រះបានស្នើសុំឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ ធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ នឹងមិនចាំបាច់ដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរនោះទេ ។

- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ បានលើកទឡ្ហីករណ៍ប្រឆាំងនឹងការយោងឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅលើទំព័រដំបូងក្នុងក្រុមមេធាវីនីមួយៗ។
- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៤ បានឯកភាពជាមួយអំណះអំណាងរបស់មេធាវីក្រុមទី២។
- អង្គជំនុំជម្រះបានចង្អុលបង្ហាញថានឹងចេញសេចក្តីសម្រេចទៅលើបញ្ហានេះនៅពេលក្រោយ។

**<u>កំណត់ហេតុនៃដំណើរការនីតិវិធី វិធាន ៨៧៖</u>**

| លេខយោង | ឈ្មោះ/សេចក្តីអត្ថាធិប្បាយ | ផ្សេងៗ |
|---|---|---|
| E3/17 | កំណត់ហេតុសួរចម្លើយខុច ដោយសហចៅក្រមស៊ើបអង្កេត ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ | D30 |
| E3/18 | ឧបសម្ព័ន្ធ ២៤៖ ៣១៦ bbkkh ឯកសារថតចម្លងគូលីវ ចម្លើយ យី លុយ អំពីសកម្មភាពទាក់ទងរវាង មាន-ផែន និង សុផាន | D32/IV-ឧបសម្ព័ន្ធ ២៤ |
| E3/19 | ចម្លើយរបស់ខុច ទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ភុង សុន្ទរី និង ជុំ ស៊ីរ៉ាត | D93/III |
| E3/20 | ឧបសម្ព័ន្ធ១៨៖ ១៨១ bbkkh ឯកសារថតចម្លងគូលីវ ចម្លើយសារភាពរបស់ ហេង ប៊ុច ហៅ ឆាន | D32/IV-ឧបសម្ព័ន្ធ ១៨ |
| E3/21 | ឧបសម្ព័ន្ធ៤១៖ ៤១២ bbkkh ឯកសារថតចម្លងគូលីវ ចម្លើយសារភាពរបស់ មាក ទូច ហៅកែម | D32/IV-ឧបសម្ព័ន្ធ ៤១ |
| E3/22 | ឧបសម្ព័ន្ធ០៩៖ ១០៤ bbkkh ឯកសារថតចម្លងគូលីវ ចម្លើយសារភាពរបស់ មុំ វឿន ហៅមុនី | D32/IV ឧបសម្ព័ន្ធ៩ |
| E3/23 | កំណត់ហេតុសួរចម្លើយខុច ដោយសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០៧ | D11 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

១-អង្គជំនុំជម្រះបានសម្រេចថាភាគីទាំងអស់មានសិទ្ធិក្នុងការចងក្រងរាល់ឯកសារទាំងអស់ និងរូបថត ហើយចែកជូនដល់អង្គជំនុំជម្រះ និងភាគី។ ដើម្បីសម្រួលដល់ដំណើរការនីតិវិធីឱ្យមានភាពងាយស្រួល ប្រសិនបើភាគីដែលមានបំណងដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ សូមជូនដំណឹងដល់ក្រឡាបញ្ជី

នៃអង្គជំនុំជម្រះ។ ភាគីទាំងអស់មិនគួរផ្តល់យោបល់ ឬធ្វើការវិភាគទៅលើឯកសារដែលបានចងក្រងនោះទេ ។

២-ដីកាបង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៩ ។

**<u>ដីកាសម្រាប់ការលើកវារកាលសវនាការ៖</u>**

ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃស្អែក ទី ២៨ ខែមេសា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ព្រឹក ។

ភ្នំពេញ, ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៩

| | |
|---|---|
| ក្រឡាបញ្ជី | ក្រឡាបញ្ជី |
| **សែ គុល វុឌ្ឍី** | **Natacha Wexels-Riser** |